# របាយការណ៍សង្ខេប
# ការចុះអភិបាលការងារប្រយុទ្ធនឹងជំងឺអេដស៍ខេត្តព្រះសីហនុ
# នៅមន្ទីរសុខាភិបាលខេត្តព្រះសីហនុ

**ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៥**

## ១.សេចក្តីផ្តើម

នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៥ ប្រតិភូអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចុះអភិបាលការងារប្រយុទ្ធនឹងជំងឺអេដស៍របស់ គណៈកម្មាធិការ-លេខាធិការដ្ឋាន ប្រយុទ្ធនឹងជំងឺអេដស៍ ខេត្តព្រះសីហនុ នៅសាលប្រជុំមន្ទីរសុខាភិបាលខេត្តព្រះសីហនុ ដោយមានការអញ្ជើញចូលរួមពីសមាជិក-សមាជិកាលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ។

## ១. របៀបវារៈ :

ការចុះអភិបាលបានដំណើរការក្រោមរបៀបវារៈដូចខាងក្រោម ៖

១-មតិស្វាគមន៍ដោយលោក **សែន រិទ្ធីវោត** ប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្តព្រះសីហនុ

២-របាយការណ៍សកម្មភាពរបស់លេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្តព្រះសីហនុ

៣-ការបំពេញកំរងសំណួរសម្រង់ទិន្នន័យការងារអេដស៍របស់ខេត្តព្រះសីហនុ

## ២. គោលបំណង

-ដើម្បីពង្រឹងការងារដឹកនាំ សំរបសំរួល និង ទំនួលខុសត្រូវរបស់ សមាជិក-សមាជិកា លេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ។

-ដើម្បីស្វែងយល់ពីស្ថានភាពពិត ស្តីពីការរាលដាល និង ការឆ្លើយតបរបស់ លេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ។

## ៣. លទ្ធផល

ជាកិច្ចចាប់ផ្តើម លោកវេជ្ជ. **សែន រិទ្ធិវោត** ប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្តព្រះសីហនុ បានមានមតិស្វាគមន៍ ចំពោះវត្តមាន ប្រតិភូអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានចំណាយ ពេលវេលាដ៏មានតំលៃ ចូលរួមក្នុងកិច្ចប្រជុំនាពេលនេះ។

លោកប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត បានបញ្ជាក់ពី ស្ថានភាពសុខាភិបាល និង សេវាផ្សេងៗ ក្នុងកម្មវិធីអេដស៍ (២០១៤) របស់ខេត្ត រួមមាន : ស្រុកប្រតិបត្តិចំនួន ០១ មន្ទីរពេទ្យបង្អែក ០១ ចំនួន មណ្ឌលសុខភាព ១៣ កំពុងដំណើរការ ចំនួនប៉ុស្តសុខភាព ០៣ កំពុងដំណើរការ មណ្ឌលធ្វើតេស្តឈាម មាន ០៣ មណ្ឌល មណ្ឌលព្យាបាលជម្ងឺឱកាសនិយមមាន ០១ កន្លែងនៅមន្ទីរពេទ្យបង្អែកខេត្ត និង គ្លីនិកសុខភាពគ្រួសារ មាន ០១ កន្លែង ។ អង្គការក្នុងខេត្តមានចំនួន០៧ : RHAC, CPN+, KWCD, UNICEF, KHEMARA, SUN RISE , NHCC ។ *សេវាកំសាន្ត នៅខេត្តព្រះសីហនុមានចំនួន ១៤២ ស្ត្រីមានចំនួន ២២៦៣នាក់ ។ អ្នកស្ម័គ្រចិត្តមក ធ្វើ តេស្តឈាមចំនួន ២៨៦ នាក់ វិជ្ជមាន ០៥ នាក់ ស្រី ០២ នាក់ ដែលជាករណីឆ្លងថ្មី (តួលេខគិតត្រឹមចុងត្រីមាសទី៤ ឆ្នាំ២០១៤)*។

**មនុស្ស ពេញវ័យ:** អ្នកជម្ងឺសកម្មមកទទួលការព្យាបាលដោយ ឱសថប្រឆាំងមេរោគអេដស៍ ART រហូតដល់ចុងត្រីមាសទី៤ឆ្នាំ២០១៤ មានចំនួន ១៦៦៩ នាក់ ស្រី ៨៨២ នាក់ ប្រុស ៧៨៧ នាក់។

**ចំពោះកុមារ:** អ្នកជម្ងឺសកម្មមកទទួល ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ រហូតដល់ចុងត្រីមាសទី៤ ឆ្នាំ២០១៤ មានចំនួន ១៥៨ នាក់ កុមារី ៧២ នាក់ កុមារា ៨៦ នាក់។

***ការលំបាក:*** - កំណើន ក្រុមប្រឈមមុខខ្ពស់ នៅក្នុងខេត្ត

- ថវិកាអនុវត្តសកម្មភាពនៅមានកំរិត និង ការអនុម័តថវិកាយឺតយ៉ាវ

- ប្រជាពលរដ្ឋនៅតាមសហគមន៍មិនទាន់មានឆន្ទៈមកទទួលយកសេវាធ្វើតេស្តឈាមទាំងស្រុងឡើយ ។

***សំណូមពរ:*** - សុំអោយ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ផ្តល់ថវិកា សំរាប់ការប្រជុំ PAC/PAS /DAC/CAC ឱ្យបានទាន់ពេលវេលា ។

***សេចក្តីសន្និដ្ឋាន :***

- ចំពោះក្រុមប្រឈមមុខខ្ពស់ទាំងអស់ គឺគណៈកម្មាធិការ និង លេខាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្តអាចគ្រប់គ្រងបាន និងឆ្លើយតបប្រកបដោយប្រសិទ្ធភាព ។ ជាក់ស្តែងនៅបំណាច់ឆ្នាំ ២០១៤ កន្លងទៅ គឺមានករណីឆ្លងថ្មី តែ ៥ ករណីប៉ុណ្ណោះ ។

- ប៉ុន្តែចំពោះក្រុម ប្រជាពលរដ្ឋនៅតាមសហគមន៍ គឺនៅមានការលំបាក ដោយពួកគាត់ពុំទាន់មកទទួលយកសេវាធ្វើតេស្តឈាមទាំងស្រុងនៅឡើយ ដែលជាហេតុ ធ្វើឱ្យកើតឡើងនូវករណីចម្លងថ្មីដោយមិនដឹងខ្លួនជាមុន ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៥

**ប្រធានបេសកកម្ម**

**វេជ្ជ. ស៊ឹម គឹមសាន**